CARITAS CHRISTI URGET NOS



# របាយការណ៍ស្តីអំពី
# សកម្មភាពអន្តរសាសនា
# ក្នុងភូមិភាគភ្នំពេញ
# ២០១៩ - ២០២០

# របាយការណ៍ស្តីអំពី សកម្មភាពអន្តរសាសនា ក្នុងភូមិភាគភ្នំពេញ ២០១៩ - ២០២០

យោងទៅតាមឯកសារសន្ទនា និងការប្រកាសដំណឹងល្អ (១៩៩១) យើងទទួលបានបែបបទនៃការសន្ទនាចំនួន៤ប្រភេទ៖

១. កិច្ចសន្ទនា តាមរយៈជីវិត ប្រចាំថ្ងៃ

២. កិច្ចសន្ទនា តាមរយៈ សកម្មភាព

៣. កិច្ចសន្ទនា តាមរយៈ ឈ្វេងយល់ ទេវវិទ្យា

៤. កិច្ចសន្ទនា តាមរយៈ បទពិសោធសាសនា

ដោយមានការរឹតត្បិតជាច្រើន ចំពោះសកម្មភាព និងការជួបជុំនានាបែបសាសនា ចាប់តាំងពីខែមីនា ឆ្នាំ ២០២០ ព្រោះតែមេរោគឆ្លងកូវីដ-១៩ ដែលរាតត្បាតជាសកល យើងមិនមាន "សកម្មភាពដូចសព្វដង" ទាក់ទងនឹងការសន្ទនាអន្តរសាសនានោះទេ ។

ព្រះសហគមន៍ភូមិភាគភ្នំពេញ បានយកចិត្តទុកដាក់ បំពេញកិច្ចការយ៉ាងសកម្មខ្លាំងក្លាបំផុត ជាយូរឆ្នាំមកហើយ ក្នុងការសន្ទនាជាមួយព្រះពុទ្ធសាសនា រួមជាមួយឥស្លាមសាសនា ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា (Cambodian Inter-Religious Council-C.I.C) ដោយមាន លោកឪពុក អ៊ុន សុន ជាបូជាចារ្យ និងលោកគ្រូ ដួង សាវង់ ដែលប្រធានការិយាល័យអប់រំជំនឿជាតំណាង ។

ក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា (C.I.C) មានកិច្ចប្រជុំប្រចាំឆ្នាំ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ នៅក្រសួងធម្មការ និងសាសនា ដើម្បីពិភាក្សាអំពីការថែរក្សាសុខដុមរមនា និងសុខសន្តិភាព សាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ១. កិច្ចសន្ទនា តាមរយៈជីវិត ប្រចាំថ្ងៃ



ជាជីវិតការរស់នៅប្រចាំថ្ងៃរបស់ព្រះសហគមន៍កាតូលិក ជាពិសេសព្រះសហគមន៍នៅជនបទ ។ យើងមានគ្រីស្តបរិស័ទកាតូលិកតិចតួច ដែលរស់នៅក្នុងចំណោមពុទ្ធបរិស័ទនៅក្នុងភូមិ និងចែករំលែកនូវជីវិតប្រចាំថ្ងៃរបស់ពួកគេជាធម្មតា ។ កម្មវិធីអប់រំសិក្សារបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលមានសាលាមត្តេយ្យចំនួន២៧ សាលាបឋមសិក្សាចំនួន២ វិទ្យាល័យចំណេះទូទៅ១ វិទ្យាល័យចំណេះដឹងទូទៅ និងបច្ចេកទេសចំនួន១ និងវិទ្យាស្ថានចំនួន១ បានផ្តល់ឱកាសពិសេសដើម្បីធ្វើការ និងរៀនសូត្ររួមជាមួយគ្នា ទាំងព្រះពុទ្ធសាសនិក និងគ្រីស្តបរិស័ទកាតូលិក នៅក្នុងបរិយាកាសភាតរភាព ដោយគោរពគ្នាទៅវិញទៅមក និងព្យាយាមធ្វើបរិយាបន្នអប់រំ ។

*នៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ យើងមានបទពិសោធផ្ទាល់ក្នុងការបង្កើតភូមិសុខសាន្ត (នៅភូមិចំការទៀង ខេត្តតាកែវ) ដែលត្រូវបានបង្កើតឡើងនៅមុខវត្ត គឺជាសញ្ញាជាក់ស្តែងនៃការធ្វើសមាហរណកម្ម និងការគោរពគ្នាទៅវិញទៅមក មានមណ្ឌលថែរក្សាកុមារដែលមានពិការភាព មានជនពិការភាពកំពុងធ្វើការនៅមជ្ឈមណ្ឌលសិប្បកម្ម មានក្រុមគ្រួសារអ្នករស់នៅជាមួយមេរោគអេដស៍ មានចាស់ជរាដែលក្រុមគ្រួសារបោះបង់ចោល មានទាំងគ្រីស្តបរិស័ទកាតូលិក មានទាំងពុទ្ធសាសនិក ។ កុមារនៅក្នុងភូមិនេះកំពុងសិក្សានៅ*









*ក្នុងសាលាមត្តេយ្យរបស់យើង... ពួកគេទាំងនោះកំពុងរស់នៅប្រកបដោយសុខដុមរមនា និងពោរពេញដោយសេចក្ដីសុខ ព្រមទាំងជួបជុំគ្នាទៅមក ដូចជាពេលមានពិធីបុណ្យនៅវត្ត ពេលប្រារព្ធពិធីបុណ្យព្រះយេស៊ូប្រសូត ឬពេលយើងប្រារព្ធពិធីផ្សេងៗនៅក្នុងព្រះសហគមន៍កាតូលិក ។*

## ២. កិច្ចសន្ទនា តាមរយៈសកម្មភាព

យូរឆ្នាំមកហើយ នៅក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត យើងមានឱកាសទៅសួរសុខទុក្ខនៅតាមពន្ធនាគារ និងនៅតាមមន្ទីរពេទ្យ ដោយមានខ្ញុំផ្ទាល់ខ្លួន (លោកអភិបាល អូលីវីយេ) មានលោកបូជាចារ្យព្រះសហគមន៍កាតូលិក និងមានគ្រីស្តបរិស័ទ រួមជាមួយព្រះសង្ឃដែលជាថ្នាក់ដឹកនាំព្រះពុទ្ធសាសនា និងថ្នាក់ដឹកនាំឥស្លាមសាសនា នៅខេត្តតាកែវ ខេត្តកំពត និងខេត្តព្រះសីហនុ ។

មេដឹកនាំសាសនានីមួយៗ បានបង្ហាញអំពីការរាក់ទាក់ និងសេចក្ដីស្រឡាញ់ចំពោះបងប្អូនជាប់ឃុំឃាំង ឬចំពោះអ្នកជំងឺ ។ យើងមានការកម្មវិធីអធិដ្ឋាន និងប្រទានពរជ័យរួមគ្នា ។ យើងរួមគ្នាចែកអាហារ និងសម្ភារមួយចំនួនដល់បងប្អូនទាំងនោះ ។

នេះគឺជាសញ្ញាសម្គាល់មួយអំពីសេចក្ដីស្រឡាញ់ ហើយបងប្អូនជាប់ឃុំ និងអ្នកជំងឺ ក៏ដូចជាអនុរក្សពន្ធនាគារ ក៏ដូចជាបុគ្គលិកសុខាភិបាលនៅតាមមន្ទីរពេទ្យ បានពោរពេញដោយអំណរសប្បាយក្នុងពេលនោះ ដែលជាបទពិសោធខាងល្អស្មារតី និងក្នុងសាមគ្គីភាពជាក់ស្ដែងតែម្ដង ។

ជាមួយគ្នានេះដែរ យើងក៏មានកម្មវិធីជួយគ្រួសាររស់នៅជាមួយមេរោគអេដស៍ នៅខេត្តតាកែវជារៀងរាល់ឆ្នាំ រួមជាមួយថ្នាក់ដឹកនាំសាសនាក្នុងខេត្តនេះផងដែរ ។

- ២២ មីនា ២០១៨៖ នៅមន្ទីរធម្មការ និងសាសនាខេត្ត ជួយដល់គ្រួសាររស់នៅជាមួយមេរោគអេដស៍ចំនួន២០០គ្រួសារ





- ១០ មករា ២០១៩៖ នៅពន្ធនាគារ ខេត្តកំពត



លោកបូជាចារ្យ និងគ្រីស្តបរិស័ទ រួមជាមួយថ្នាក់ដឹកនាំព្រះពុទ្ធសាសនា និងឥស្លាមសាសនា





- ១១ មករា ២០១៩៖ នៅមន្ទីពេទ្យបង្អែក ខេត្តព្រះសីហនុ







ថ្នាក់ដឹកនាំអន្តរសាសនាបង្ហាញការស្វាគមន៍ និងសេចក្ដីស្រឡាញ់ដល់អ្នកជំងឺ យើងបានអធិស្ឋាន និងប្រទានពរដល់ពួកគេ

- ០៨ មករា ២០២០៖ នៅពន្ធនាគារ ខេត្តតាកែវ











- ០៩ មករា ២០២០៖ នៅពន្ធនាគារ ខេត្តកំពត








ថ្ងៃទី១៨ ឧសភា ២០២០ នៅក្នុងវិបត្តិនៃបរិបទមេរោគឆ្លងកូវីដ-១៩ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយអង្គការការីតាសកម្ពុជា បានថ្វាយម៉ាស់ និងអាល់កុលដល់ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ប្រគេនដល់មន្ត្រីព្រះសង្ឃ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ រាជធានីភ្នំពេញ ក៏ដូចជាបានប្រគល់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ នៃឥស្លាមសាសនានៅកម្ពុជាផងដែរ ។







ក្នុងឆ្នាំ២០២០ ៖ លោកអភិបាលអូលីវីយេ ជ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានស្នាក់នៅក្នុងភូមិក្នុងខេត្តតាកែវជាច្រើនសប្តាហ៍ ក្នុងអំឡុងពេលមានវិបត្តិដោយសារជំងឺឆ្លងរាតត្បាតកូវីដ១៩ ហើយនេះក៏ជាឱកាស ក្នុងពង្រឹងទំនាក់ទំនងជាមួយបងប្អូនពុទ្ធបរិស័ទ ជាពិសេសជាមួយវត្ត និងជាមួយព្រះសង្ឃ ។







នៅខែ ឧសភា ២០២០ ព្រះសង្ឃ និងពុទ្ធបរិស័ទ បានជ្រើសតាំងលោកអភិបាលអូលីវីយេ ធ្វើជាប្រធានក្រុមបរិស្ថាននៅវត្តអង្គមន្ត្រី (ខេត្តតាកែវ) ។ លោកអភិបាលបានជូន រោងកសិដ្ឋានដាំបន្លែដល់វត្ត ដើម្បីជាប្រយោជន៍ដល់ព្រះសង្ឃដាំដុះបន្លែសរីរាង្គសម្រាប់សហគមន៍ផ្ទាល់ខ្លួនបាន ។ ដោយសាររោងកសិដ្ឋានបន្លែនេះមានភាពល្បីល្បាញ នាំឲ្យមានព្រះសង្ឃ និងពុទ្ធបរិស័ទពីវត្តនានាជាច្រើនទៀតក្នុងតំបន់នោះ បានមកសិក្សា និងទស្សនកិច្ច ហើយមានទាំងលោកអភិបាលស្រុក និងជាពិសេស គឺទីប្រឹក្សាផ្ទាល់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានទស្សនកិច្ច រោងកសិដ្ឋានបន្លែនេះផងដែរ ។





នាថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ លោកអភិបាលអូលីវីយេ បានចូលជួបសម្តែងការគួរសមចំពោះសម្តេចអគ្គព្រះមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងឱកាសចូលឆ្នាំថ្មីឆ្នាំសកល ដើម្បីបង្ហាញពីមិត្តភាពរបស់ព្រះសហគមន៍កាតូលិក ចំពោះសម្តេចអគ្គព្រះមហាសង្ឃរាជាធិបតី ទេព វង្ស (ព្រះជន្មាយុ ៩០ ព្រះវស្សា) ក្នុងអំឡុងពេលព្រះអង្គស្ថិតក្នុងព្រះរាជសុខភាពទន់ខ្សោយ ។



នេះគឺជា ឱកាសដ៏ពិសេស ដើម្បីថ្លែងព្រះអំណរគុណចំពោះសម្តេចព្រះសង្ឃរាជ ដែលព្រះអង្គមានព្រះរាជសកម្មភាពយ៉ាងសកម្ម ក្នុងកិច្ចសន្ទនាអន្តរសាសនាជាយូរឆ្នាំកន្លងមក(សម្តេច បានយាងចូលរួមអង្គប្រជុំអន្តរសាសនាអន្តរជាតិ នៅទីក្រុង អាស៊ីស៊ី រួមជាមួយសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ និងអង្គប្រជុំអន្តរសាសនាជាច្រើនទៀតដែលរៀបចំដោយសមាគមសន្តអេជីដេអូ) ។ យើងក៏មានសេចក្តីសោមនស្ស ចំពោះទំនាក់ទំនងល្អនៅក្នុងប្រទេសកម្ពុជា តាមរយៈការជួបជុំសន្ទនាអន្តរសាសនាជាច្រើនកន្លងមក ។

ទំនាក់ទំនងដ៏ល្អរវាងសាសនា និងសាសនានៃយើង ពិតជាបង្កើតឲ្យមានសន្តិភាព និងសុខដុមរមនានៅក្នុងសង្គមកម្ពុជារបស់យើងសព្វថ្ងៃ ។

សម្តេចព្រះសង្ឃរាជ ប្រទានពរដល់គ្រីស្តបរិស័ទកាតូលិក និងថ្នាក់ដឹកនាំទាំងអស់ ឱ្យមានសុខភាពល្អ មានវិបុលភាព និងសេចក្តីសុខសាន្តនៅក្នុងដួងចិត្ត ។ នេះគឺជាបទពិសោធមួយដ៏សាមញ្ញនៃភាតរភាព ។





## ៣. កិច្ចសន្ទនា តាមរយៈ ឈ្វេងយល់ ទេវវិទ្យា

លោកអភិបាល អូលីវីយេ ផ្មិតហស្លេ បានបបង្កើត វិទ្យាស្ថានសន្តប៉ូលក្នុងឆ្នាំ២០១០ ដែលជាគ្រឹះស្ថានឧត្តមសិក្សាកាតូលិកតែមួយគត់ ផ្តល់ការអប់រំកម្រិតបរិញ្ញាបត្រ ។ ខ្ញុំបានបង្កើតឱ្យមាន "សិក្ខាសាលាស្រាវជ្រាវ" ចាប់តាំងពីឆ្នាំ ២០១៤ មក ។ នេះជាសិក្ខាសាលាដែលមានរយៈពេល៣ថ្ងៃ ។ នៅថ្ងៃទី០២ ពេញមួយថ្ងៃ សម្រាប់ព្រះសហគមន៍កាតូលិក ព្រះពុទ្ធសាសនា និងឥស្លាមសាសនា ដើម្បីចែករំលែកទស្សនៈរបស់ខ្លួនទៅលើប្រធានបទស្រាវជ្រាវរបស់យើង ។

ចំពោះសិក្ខាសាលាក្រោយៗទៀត គឺប្រធានបទនិយាយអំពី ការថែរក្សាបរិស្ថាន/ LAUDATO SI និងគ្រួសារ / AMORIS LAETITIA








ជាពេលវេលាពិសេសសម្រាប់និស្សិត និងសាស្ត្រាចារ្យជាសិក្ខាកាម ចំនួន១៥០នាក់ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិល ព្រមទាំងតំណាងអង្គការក្រៅរដ្ឋាភិបាល ដើម្បីរិះគិត និងឈ្វេងយល់ឱ្យបានស៊ីជម្រៅ ចំពោះគ្នាទៅវិញទៅមក សម្រាប់សេចក្តីត្រូវការរួមក្នុងសង្គម ។

## ៤. កិច្ចសន្ទនា តាមរយៈពិសោធសាសនា

ចំណុចនេះ ដូចជាពិបាកក្នុងការទទួលយកបន្តិច ប៉ុន្តែតាមរយៈដំណើរទស្សនកិច្ចទៅកាន់ពន្ធនាគារ យើងអធិដ្ឋានតាមប្រពៃណីសាសនារបស់យើងផ្ទាល់ខ្លួន ។ យើងបកប្រែសារលិខិតរបស់ក្រសួង សម្រាប់ការសន្ទនាអន្តរសាសនាជារៀងរាល់ឆ្នាំ ក្នុងឱកាសនៃពិធីបុណ្យវិសាខបូជា ហើយបានស្នើសុំលោកបូជាចារ្យតាមព្រះសហគមន៍កាតូលិក ទៅទស្សនកិច្ចតាមវត្តដែលនៅជិតព្រះសហគមន៍កាតូលិក ដើម្បីប្រគេនសារលិខិតជូនពរនេះទៅព្រះសង្ឃ ។

ខ្ញុំក៏មានសកម្មភាពជាក់ស្តែងមួយចំនួនដូចជា៖

- ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ មានសាររួមគ្នាមួយ ពីព្រះសង្ឃ និងលោកអភិបាលអូលីវីយេ ដើម្បីជូនពរដល់ពុទ្ធសាសនិក និងគ្រីស្តបរិស័ទកាតូលិកក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

- ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០ បានចូលរួមពិធីបុណ្យវិសាខបូជានៅវត្ត







- ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ លោកអភិបាលអូលីវីយេ បានចូលរួម "បុណ្យផ្កា" ដើម្បីដង្ហែទៅវត្ត និងបានថ្លែងសន្ទរកថា ជូនបងប្អូនពុទ្ធបរិស័ទ អំពីការថែរក្សាបរិស្ថាន (INTEGRAL ECOLOGY).







ថ្ងៃសុក្រ ទី០៦ ធ្នូ ២០១៩ ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស បំពាក់មេដាយមាសស្ថាបនាជាតិពីរាជរដ្ឋាភិបាលកម្ពុជា ជូនខ្ញុំ សម្រាប់រយៈពេល ១៧ឆ្នាំនៃទំនាក់ទំនងជិតស្និទ្ធជាមួយព្រះពុទ្ធសាសនា ។









**សុខដុមរមនា សន្តិភាព កិច្ចសន្ទនា ការចែករំលែកគុណតម្លៃនៃជីវិតខាងផ្លូវវិញ្ញាណ**

គឺជាបេសកកម្មរបស់យើងជាសាសនទូតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ យើងនឹងបន្តនូវកិច្ចខិតខំប្រឹងប្រែងទៅមុខទៀត ដើម្បីអត្ថន័យដ៏វិសេសវិសាលដល់មនុស្សជំនាន់ក្រោយ!


រៀបចំរបាយការណ៍ដោយ៖

\+ លោកអភិបាល អូលីវីយេ ឌ្មិតហាស្លេ

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

នៃព្រះរាជាណាចក្រកម្ពុជា